REDD+ CAMBODIA

# ព្រឹត្តិបត្រប្រចាំត្រីមាស

លេខ ៧ ៨ និង ៩
ខែតុលា ឆ្នាំ ២០១៤ រហូត ខែមិថុនា ឆ្នាំ ២០១៥
ក្រុមការងាររេដបូកកម្ពុជា



## ក្រុមប្រឹក្សាភិបាលកម្មវិធីដាក់ចេញរបៀបវារៈដ៏មានមហិច្ឆិតាសម្រាប់រេដបូក ឆ្នាំ២០១៥

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលកម្មវិធី UN-REDD និងគម្រោងភាពជាដៃគូកាបូនព្រៃឈើ (FCPF) លើកទី៩បានប្រព្រឹត្តនាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ។ សមាសភាពក្រុមប្រឹក្សាភិបាលកម្មវិធី រួមមាន តំណាងមកពីរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន អង្គការ UNDP FAO UNEP ជនជាតិដើមភាគតិច អង្គការសង្គមស៊ីវិល ស្ថានទូតជប៉ុន ន័រវេ៉ និងដៃគូអភិវឌ្ឍន៍ JICA និង EU។

ឯកឧត្តម បណ្ឌិត ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ និងជាសហប្រធានក្រុមប្រឹក្សាកម្មវិធីUN-REDD និងគម្រោង FCPF បានគូសបញ្ជាក់ពីវឌ្ឍនភាព សំខាន់ៗពាក់ព័ន្ធការអនុវត្តសកម្មភាពរេដបូកកម្ពុជានាឆ្នាំ២០១៤។ ឯកឧត្តម ក៏បានគូសបញ្ជាក់បន្ថែមពីវឌ្ឍនភាព ដែលសម្រេចបានជុំវិញការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និង អបអរសាទរដែលបានឃើញសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកដំបូងបានលេចចេញជារូបរាង និងផែនទីបង្ហាញផ្លូវសម្រាប់ការពិគ្រោះយោបល់និងការរៀបចំបញ្ចប់យុទ្ធសាស្ត្ររេដបូកជាតិ ក៏ត្រូវបានរៀបចំរួចរាល់ផងដែរ។ ក្រុមប្រឹក្សាភិបាលកម្មវិធី UN-REDD និងគម្រោងFCPF បានដាក់ចេញនូវគោលដៅ និងទិសដៅដ៏មានមហិច្ឆិតា រួមមាន ការបង្ហាញយុទ្ធសាស្ត្ររេដបូកជាតិ និងកម្រិតបំភាយយោងនៅក្នុងសន្និសិទ្ធនៃបណ្តាប្រទេសជាភាគីលើកទី២១ (COP21) អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងប្រព្រឹត្តទៅនាខែធ្នូ ឆ្នាំ២០១៥ នៅទីក្រុងប៉ារីស ខាងមុខនេះ។

លោកស្រី Claire Van der Vaeren អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងជាសហប្រធានក្រុមប្រឹក្សាភិបាល UN-REDD និងគម្រោង FCPF បានគាំទ្រដល់ដំណើរការពិគ្រោះយោបល់ដើម្បីទទួលបានការគាំទ្រកម្រិតខ្ពស់ពីក្រសួងពាក់ព័ន្ធនានាដល់ការអនុវត្តសកម្មភាពរេដបូកនៅកម្ពុជា។ លោកស្រីក៏បានគូសបញ្ជាក់ថាយុទ្ធសាស្ត្ររេដបូកជាតិគួរធានាយ៉ាងណាឲ្យសម្លេងសហគមន៍ក្រីក្រដែលរស់នៅពឹងអាស្រ័យផលព្រៃឈើ រួមមាន

ជនជាតិដើមភាគតិច ស្ត្រី ក្រុមមនុស្សចាស់ និងយុវជនត្រូវបានដឹងឮ និងពិចារណានៅក្នុងដំណើរការកិច្ចពិគ្រោះយោបល់ ។

ក្រុមប្រឹក្សាភិបាល បានអនុម័តលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០១៥ សម្រាប់គម្រោង FCPF និងកត់សម្គាល់ពីសមិទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ២០១៤ និងការអនុម័តលើផែនការប្រចាំប្រទេសនៃកម្មវិធីរេដបូកនៅសហគមន៍ និងការចាប់ផ្តើមអនុវត្តផែនការនេះ។ ក្រុមប្រឹក្សាភិបាល ក៏បានកត់សម្គាល់ពីការរៀបចំយន្តការពេលខាងមុខសម្រាប់ការអនុវត្តលទ្ធផលទី៤ របស់គម្រោង FCPF រវាងលេខាធិការដ្ឋានរេដបូកUNDPនិងអង្គការFAOផងដែរ។

ក្រុមប្រឹក្សាភិបាល ក៏បានអនុម័តលើសំណើរសម្រាប់ការវាយតម្លៃបញ្ចប់កម្មវិធី UN-REDD ដែលនឹងចាប់ផ្តើមអនុវត្តនៅ ខែមេសា ឆ្នាំ២០១៥ ហើយរង់ចាំពិនិត្យលើលទ្ធផល និងអនុសាសន៍វាយតម្លៃកម្មវិធីនេះ នៅក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាភិបាលគម្រោងដែលជាដំណើរការបន្តដើម្បីពង្រឹងការអនុវត្តកម្មវិធីរេដបូកនៅកម្ពុជា។

## តំណាងជនជាតិដើមភាគតិចក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូក

កិច្ចប្រជុំស្តីពីការជ្រើសរើសតំណាងជនជាតិដើមភាគតិចដើម្បីចូលរួមនៅក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកបានរៀបចំឡើងនាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ដែលមានតំណាងប្រមាណ៣០នាក់មកពីជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងអន្តរជាតិ និងលេខាធិការដ្ឋានរេដបូកកម្ពុជាចូលរួមក្នុងព្រឹត្តិការណ៍នេះ។កិច្ចប្រជុំក៏បានពិនិត្យនិងផ្តល់អនុសាសន៍ កែលម្អលើយន្តការលំហូរព័ត៌មាន និងការផ្តល់ព័ត៌មានត្រឡប់ស្តីពីគោលនយោបាយ និងសកម្មភាពរេដបូកផងដែរ។ អ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំនេះរួមមានតំណាងមកពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ (RECOFTC) និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS)។តំណាងជនជាតិដើមភាគតិចអញ្ជើញមកពីខេត្តចំនួន ១៣ បានពិភាក្សា និងអនុម័តតួនាទីភារកិច្ចដែលនឹងណែនាំតម្រង់ទិសដល់ការចូលរួមរបស់ខ្លួននៅក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា។ តំណាងជនជាតិដើមភាគតិច ក៏បានបោះឆ្នោតជ្រើសរើស លោក ម៉ែន ប៉ាក់ ជាតំណាងជនជាតិដើមភាគតិច និង លោក លី លឹម ជាតំណាងបំរុងជំនួសសម្រាប់ចូលរួមជាសមាជិកក្រុមប្រឹក្សាគម្រោងភាពជាដៃគូកាបូនព្រៃឈើ (FCPF) និងក្រុមប្រឹក្សាយោបល់រេដបូកបន្ទាប់ពីលោក ណុក វេន បានលាលែងពីសមាជិកក្រុមប្រឹក្សាភិបាលគម្រោងនាខែកុម្ភៈ ឆ្នាំ២០១៥កន្លងមកនេះ។

លោក បណ្ឌិត ឃុន សាវ៉េត ប្រធានលេខាធិការដ្ឋានរេដបូកកម្ពុជា បានសម្តែងនូវការអបអរសាទរចំពោះបេក្ខជនដែលបានជាប់ឆ្នោត និងបានគូសបញ្ជាក់ថាលេខាធិការដ្ឋាន នឹងបន្តពង្រឹងការចូលរួមរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកឲ្យកាន់តែមានប្រសិទ្ធភាព។



លោក ម៉ែន ប៉ាក់ បានប្តេជ្ញាចិត្តចំពោះមុខ តំណាងជនជាតិដើមភាគតិចថានឹងប្រឹងប្រែងធ្វើការងារប្រកបដោយប្រសិទ្ធិភាពជាមួយនឹងសមាជិករបស់សហគមន៍មូលដ្ឋាន រដ្ឋាភិបាល និង ភាគីពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជាអោយទទួលបានជោគជ័យ។ តំណាងជនជាតិដើមភាគតិច ក៏បានឯកភាពពិនិត្យឡើងវិញលើវឌ្ឍនភាព និងបញ្ហាប្រឈមនានាជាទៀងទាត់ផងដែរ។

## កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីផ្តល់មតិយោបល់ដល់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ

ចាប់តាំងពីខែមករា ឆ្នាំ២០១៥មក លេខាធិការដ្ឋានរេដបូកកម្ពុជាបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើក លើសេចក្តីព្រាងបឋមយុទ្ធសាស្ត្ររេដបូកជាតិ ជាមួយអ្នកពាក់ព័ន្ធ និងសមាជិកក្រុមជំនាញបច្ចេកទេសរេដបូក។សេចក្តីព្រាងលើកទី២នៃយុទ្ធសាស្ត្ររេដបូកជាតិ បានពិចារណាកែសម្រួលដាក់បញ្ចូលយោបល់ និងអនុសាសន៍ ដែលទទួលបានពីកិច្ចពិគ្រោះយោបល់ទាំងនេះ។

បន្ទាប់មក នាថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០១៥ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ បានរៀបចំឡើងក្នុងគោលបំណងបង្ហាញពីវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រ ប្រមូលមតិយោបល់ផ្នែកបច្ចេកទេស និងការព្រួយបារម្ភនានាពីអ្នកចូលរួម និងអ្នកជំនាញបច្ចេកទេសប្រមាណជាង ៧០នាក់ ដែលជាសមាជិករបស់ក្រុមការងាររេដបូក ក្រុមការងារបច្ចេកទេស ក្រុមប្រឹក្សាយោបល់ ក្រុមយេនឌ័រ និងក្រុមអ្នកជំនាញបច្ចេកទេសរេដបូក ដើម្បីកំណត់ពីបញ្ហានានាដែលត្រូវការមតិយោបល់បន្ថែមទៀត ដើម្បីកែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្ររេដបូកជាតិ សម្រាប់ដាក់ក្នុងវេទិកាពិគ្រោះយោបល់បន្តបន្ទាប់ទៀតឲ្យកាន់តែមានសុក្រឹត្យភាព។ កិច្ចប្រជុំពិគ្រោះយោបល់នេះ គឺជាវេទិកា សម្រាប់ឲ្យអ្នកពាក់ព័ន្ធរួមចំណែកផ្តល់មតិយោបល់លើជំនាញ បច្ចេកទេស និងលើកឡើងពីការព្រួយបារម្ភនានា ដើម្បីដាក់ចូលបន្ថែមក្នុងដំណាក់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ។ ព័ត៌មានលំអិតអំពីសកម្មភាពពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធទាំងអស់ នឹងត្រូវចងក្រងទុកជាឯកសារសារតារយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីបង្ហាញ និងធានាគណនេយ្យភាព និងតម្លាភាពនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

សេចក្តីព្រាងលើកទី២នៃយុទ្ធសាស្ត្ររេដបូកជាតិ បង្ហាញពីទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃឈើនៅកម្ពុជាសម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ក្របខ័ណ្ឌ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក ការរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ កម្រិតបំភាយយោងពីព្រៃឈើ និងការរៀបចំស្ថាប័នសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ។



សេចក្តីព្រាងផែនការយុទ្ធសាស្ត្រនេះ គូសបញ្ជាក់ផងដែរពីសារសំខាន់នៃការបញ្ជ្រាបយេនឌ័រ ក៏ដូចជាការទទួលយកសម្លេងពីអង្គការសង្គមស៊ីវិល ជនជាតិដើមភាគតិច សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារនិងសហគមន៍នេសាទ។

លោកស្រី វង្ស សុបញ្ញា អនុប្រធានរដ្ឋបាលព្រៃឈើមានប្រសាសន៍នៅក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ថា រាជរដ្ឋាភិបាលកម្ពុជាគាំទ្រយ៉ាងខ្លាំងដល់ការរៀបចំ និងអនុវត្តរេដបូកនៅកម្ពុជា ដែលជាជម្រើសមួយដ៏ល្អ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការបំភាយឧស្ម័នពីវិស័យព្រៃឈើ និងរួមចំណែកចំពោះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ការអនុវត្តសកម្មភាពនេះ នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងសម្រេចបាននូវនិរន្តរភាពបរិស្ថាន។

សិក្ខាកាមចូលរួមនៅក្នុងកិច្ចប្រជុំនេះបានបែងចែកជា៥ក្រុម ដើម្បីពិភាក្សា និងផ្តល់មតិយោបល់អំពីវិសាលភាព និងកម្រិតនៃការអនុវត្តសកម្មភាពរេដបូក កត្តាដែលនាំឲ្យមានការបាត់បង់ និងការរេចរឹលព្រៃឈើ ក៏ដូចជាគោលនយោបាយ និងវិធានការនានា ដើម្បីអនុវត្តសកម្មភាពរេដបូកនៅកម្ពុជា។

## ការបណ្តុះបណ្តាលស្តីពីការកសាងឧបករណ៍ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS tools)សម្រាប់វិភាគសេដ្ឋកិច្ចរេដបូកនៅកម្ពុជា

ការបណ្តុះបណ្តាល និងការពិភាក្សា បានប្រព្រឹត្តិទៅនាថ្ងៃទី១៥-១៩ ខែមិថុនា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលរេដបូកនៃរដ្ឋបាលព្រៃឈើ។ ការបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួន១៥នាក់ដែលមកពីរដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអង្គការមិនមែនរដ្ឋាភិបាល បានទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់ Quantum GIS និងពិភាក្សាជាមួយអ្នកជំនាញមកពីអង្គការ UNEP-WCMC ដើម្បីធ្វើការអនុវត្តសាកល្បង និងបន្តរៀបចំឧបករណ៍ GIS ដែលដាក់បញ្ចូលទិន្នន័យសេដ្ឋកិច្ច និងទិន្នន័យស្ពេតសល (Spatial Data)។ ការវិភាគទិន្នន័យសេដ្ឋកិច្ច និងស្ពេតសល



ទិន្នន័យត្រូវបានធ្វើឡើងដើម្បីផ្តល់ការគាំទ្រដល់ការរៀបចំផែនការរេដបូកក្រោមកម្មវិធីរេដបូកជាតិ។

ការបណ្តុះបណ្តាល ដែលមានរយៈពេល ៥ ថ្ងៃ បានរួមចំណែកយ៉ាងសំខាន់ដល់ការកសាងឧបករណ៍ GIS និងបង្កើនការយល់ដឹងអំពីការចំណាយ និងផលប្រយោជន៍នៃជម្រើសផ្សេងគ្នា សម្រាប់ការអនុវត្តរេដបូក អាស្រ័យទៅតាម Spatial Data។ វគ្គបណ្តុះបណ្តាលនេះ ក៏បានបង្កើនសមត្ថភាពរៀបចំ ប្រើប្រាស់ និងអនុវត្តឧបករណ៍ គាំទ្រដល់ការសម្រេចចិត្តនៅក្នុងការរៀបចំផែនការរេដបូក ដែលសកម្មភាពនេះកំពុងត្រូវបានអនុវត្តតាមរយៈការសហការរវាងអង្គការ UNEP-WCMC និងកម្មវិធីរេដបូកជាតិកម្ពុជា។

វគ្គបណ្តុះបណ្តាលនេះរួមមាន ការធ្វើបទបង្ហាញ ការពិភាក្សា សំណួរ និងចម្លើយ ព្រមទាំងការអនុវត្តដោយផ្ទាល់ផងដែរ ជាពិសេស ផ្តោតការយកចិត្តទុកដាក់លើការប្រើប្រាស់ Quantum GIS ដែលជា ឧបករណ៍ GIS ថ្មីនិងការរៀបចំលំហូរការងារ ដែលនឹងផ្តល់ព័ត៌មានដល់ការរៀបចំឧបករណ៍បន្ថែមទៀត ដោយធ្វើការកែសម្រួលឲ្យស្របតាមបរិបទរបស់ប្រទេសកម្ពុជា។ តាមរយៈការបណ្តុះបណ្តាល និងកិច្ចប្រជុំពិភាក្សា អ្នកចូលរួមមានឱកាសកសាងជំនាញរបស់ខ្លួនលើការវិភាគ Spatial Data ដើម្បីគាំទ្រដល់ស្ថាប័នរបស់ខ្លួន ក្នុងការឆ្លើយតប ចំពោះទិដ្ឋភាពចម្រុះពាក់ព័ន្ធនឹងការរៀបចំផែនការ និងការអនុវត្តរេដបូក។

ទាក់ទងនឹងការងារនេះ លេខាធិការដ្ឋានក្រុមការងាររេដបូកកម្ពុជា នឹងរៀបចំបញ្ចប់ Web platform សម្រាប់ប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើជាតិដែលនឹងដាក់ឲ្យដំណើរការនៅក្នុងគេហទំព័រ Cambodia-redd.org នៅក្នុងពេលខាងមុខនេះ។

## ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីរេដបូកជាតិ

ពិតជាមានសារសំខាន់ណាស់ដែលបញ្ហាយេនឌ័រត្រូវបានដោះស្រាយនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ដូច្នេះដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រ នៅក្នុងតំណាក់កាលត្រៀមលក្ខណៈអនុវត្តរេដបូក។ ប្រទេសកម្ពុជាបាននឹងកំពុងចាត់វិធានការជាជំហានៗ ដើម្បីដោះស្រាយបញ្ហាយេនឌ័រ នៅក្នុងវិស័យព្រៃឈើ តាមរយៈសកម្មភាពរេដបូក។ ផ្អែកលើជំហានវិជ្ជមានដំបូងនេះ ដើម្បីធានាឲ្យមានការដាក់បញ្ចូលការឆ្លើយតបចំពោះបញ្ហាយេនឌ័រទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ ចាំបាច់ត្រូវកសាងសមត្ថភាព និងបង្កើនការយល់ដឹងស្តីពីយេនឌ័រដល់ក្រុមការងារយេនឌ័ររេដបូក ក្រុមបច្ចេកទេសរេដបូក ក្រុមប្រឹក្សាយោបល់រេដបូក និងក្រុមការងាររេដបូកកម្ពុជា។

ជាអាទិ៍កាលពីខែសីហា ឆ្នាំ២០១៤ ក្រុមការងារយេនឌ័ររេដបូកត្រូវបានបង្កើតឡើងដោយមានសមាជិកមកពីស្ថាប័នពាក់ព័ន្ធចំនួន ៤ រួមមានរដ្ឋបាលព្រៃឈើរដ្ឋបាលជលផល ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។ ក្រុមការងារនេះមានភារកិច្ចបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ជូនដល់សមាជិកក្រុមការងាររេដបូកកម្ពុជា ក្រុមការងារបច្ចេកទេសទាំង ៤ (MRV, Safeguards, Demonstration, Benefit Sharing) និងដល់ក្រុមប្រឹក្សាយោបល់រេដបូក។ ក្រុមការងារនេះ ក៏មានតួនាទី ផ្តល់យោបល់លើចំណុចសំខាន់ៗនានានៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ដើម្បីធានាយ៉ាងណាឲ្យយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តរេដបូក មានតុល្យភាព និងឆ្លើយតបចំពោះបញ្ហាយេនឌ័រ។

បន្ទាប់មក ចាប់តាំងពីខែមេសា រហូត ខែឧសភា ឆ្នាំ២០១៥ ក្រុមការងារយេនឌ័ររេដបូក បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន ២លើក ស្តីពីទស្សនទានយេនឌ័រ និងរេដបូក នៅខេត្តព្រះសីហនុ និងខេត្តសៀមរាប ជូនដល់សមាជិកក្រុមការងាររេដបូក ក្រុមបច្ចេកទេសទាំង ៤ និងក្រុមប្រឹក្សាយោបល់រេដបូក។ សិក្ខាសាលានេះមានគោលបំណងបង្កើនការយល់ដឹងអំពីទស្សនទានយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ព្រមទាំងធ្វើការពិភាក្សា និងកំណត់នូវ ចំណុចចាប់ផ្តើម សម្រាប់បញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងសកម្មភាពនឹងកម្មវិធីរេដបូក ណែនាំនិងពិភាក្សាពីរបៀបប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់យេនឌ័រ (Gender CheckList) សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យលើការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។



លោកបណ្ឌិត យន សារ៉េត ប្រធានលេខាធិការដ្ឋានរេដបូកកម្ពុជា បានគូសបញ្ជាក់ពីសារសំខាន់នៃការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ លោកក៏បានលើកទឹកចិត្តអ្នកចូលរួមឲ្យយកចិត្តទុកដាក់ក្រេបយកចំណេះដឹង អំពីទស្សនទានយេនឌ័រហើយយកទស្សនទានទាំងនេះទៅអនុវត្តនៅក្នុងកម្មវិធីរេដបូកអោយមានប្រសិទ្ធភាពខ្ពស់។ បន្ថែមពីនេះលោកក៏បានរំលឹកឡើងវិញពីតួនាទីសំខាន់របស់ក្រុមការងារបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូកក្នុងការផ្តល់ការគាំទ្រដល់ក្រុមការងាររេដបូកកម្ពុជាសម្រាប់ដំណាក់កាលត្រៀមលក្ខណៈអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ។

សិក្ខាកាមចំនួន ៨៩នាក់ មកពី ខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តសៀមរាប កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ សមាជិកក្រុមប្រឹក្សាយោបល់រេដបូក ក្រុមការងារបច្ចេកទេសរេដបូកទាំង ៤ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែ និងថាមពល ក្រសួងកិច្ចការនារី និងក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ព្រមទាំង តំណាងមកពីដៃគូអភិវឌ្ឍន៍ JICA, CAM REDD និង UNDP បានចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលដ៏មានសារសំខាន់នេះ។

សមាជិកក្រុមការងារយេនឌ័ររេដបូក គឺជាអ្នកសម្របសម្រួល វគ្គបណ្តុះបណ្តាល ដោយប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្របណ្តុះបណ្តាលចំរុះ រួមមានការធ្វើបទបង្ហាញ ការពិភាក្សាក្រុម និងទស្សនា វីដេអូករណីសិក្សាពីប្រទេសជិតខាង ព្រមទាំងការអនុវត្តផ្ទាល់ដើម្បីធានាដល់ការចូលរួមសកម្មពីសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

**លទ្ធផលទទួលបានពីសិក្ខាសាលាបណ្តុះបណ្តាលនេះរួមមានខ្លឹមសារដូចខាងក្រោម៖**

- អ្នកចូលរួមបានយល់ដឹងពីទស្សនទានយេនឌ័រនិងឧបករណ៍សម្រាប់ការវិភាគបញ្ហាយេនឌ័រ
- អ្នកចូលរួមបានយល់ដឹងពីវិធីសាស្ត្របញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងវិស័យព្រៃឈើតាមរយៈការសិក្សាបទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ីនិងវៀតណាម
- អ្នកចូលរួមបានពិនិត្យនិងសាកល្បងប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់យេនឌ័រនៅក្នុងការពិនិត្យ លើយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីធានាដល់ការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងសេចក្តីព្រាងដំបូងយុទ្ធសាស្ត្ររេដបូកជាតិ ដែលជាលទ្ធផលមានការរកឃើញថាការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិនៅមានកម្រិតនៅឡើយ។

**ការពិភាក្សា៖**

សិក្ខាកាម បានផ្តល់ជាអនុសាសន៍ស្នើសុំឲ្យមានការសម្រួលបញ្ជីផ្ទៀងផ្ទាត់យេនឌ័រឲ្យស្របទៅតាមបច្ចុប្បន្នភាពនៃសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ។ សិក្ខាកាមក៏បានកត់សំគាល់ផងដែរថា បញ្ជីផ្ទៀងផ្ទាត់យេនឌ័រ គឺជាឧបករណ៍ដ៏សំខាន់ ដែលជួយសម្រួលឲ្យពួកគាត់ងាយស្រួលយល់ពីចំណុចខ្វះខាតនានានៅក្នុងការដាក់បញ្ចូលបញ្ហាយេនឌ័រ នៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្រនេះ។

សិក្ខាកាម ក៏បានផ្តល់អនុសាសន៍ សម្រាប់កែលំអរលើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិផងដែរ ដោយបានស្នើសុំអោយបន្ថែមចំណុចសំខាន់ៗ ដែលមានចែងពីការគិតគូរពីបញ្ហាយេនឌ័រស្របតាមរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី ការបង្កើនការយកចិត្តទុកដាក់លើការបញ្ជ្រាប និងការចូលរួមរបស់ជនជាតិដើមភាគតិច

ទស្សនវិស័យរបស់ស្ត្រី និងការចូលរួមរបស់សហគមន៍ សេចក្តីណែនាំ និងយន្តការច្បាស់លាស់ទាក់ទងនឹងការទទួលបានព័ត៌មានដោយសេរី ជាមុន និងដោយមានការឯកភាពយល់ព្រម (FPIC) ការបែងចែកទិន្នន័យ និងសូចនាករ តាមភេទ ការបង្កើតយន្តការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាព យន្តការផ្តល់មូលនិធិ និងការបែងចែកផលប្រយោជន៍ ការបញ្ជាក់ឲ្យបានច្បាស់ពីតួនាទីយេនឌ័រនៅក្នុងសកម្មភាព វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) និងការតាមដានកម្រិតបំភាយយោង (REL)។

មតិយោបល់មតិ និងអនុសាសន៍ ដែលបានមកពីសិក្ខាសាលានេះ ត្រូវបានផ្តល់ជូនក្រុមការងាររៀបចំយុទ្ធសាស្ត្រ ដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិជាបន្តបន្ទាប់។

បន្ថែមលើវគ្គបណ្តុះបណ្តាលនេះ នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ សមាជិកក្រុមការងារយេនឌ័ររេដបូក ក៏បានចូលរួមជាវាគ្មិនក្នុងកម្មវិធីកិច្ចពិភាក្សាស្តីពីរេដបូកនៅក្នុងកម្មវិធីវិទ្យុ និងទូរទស្សន៍ ដើម្បីបង្កើនការផ្សព្វផ្សាយការយល់ដឹងអំពីទស្សនៈទានយេនឌ័រ និងរេដបូកដល់និស្សិត និងសាធារណៈជនទូទៅផងដែរ។

## ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីរេដបូក

កម្មវិធីរេដបូកជាតិ កំពុងបន្តសកម្មភាពផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីរេដបូក តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ហ្វេសប៊ុក និងគេហទំព័រជាដើម។ នាឆ្នាំ២០១៤ លេខាធិការដ្ឋានរេដបូកកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយទូរទស្សន៍ជាតិកម្ពុជា និងមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (វិទ្យុ FM ១០២) ដើម្បីផលិតកម្មវិធីផ្សព្វផ្សាយពាក់ព័ន្ធ



សកម្មភាពរេដបូកនៅកម្ពុជា។ កម្មវិធីទូរទស្សន៍កិច្ចពិភាក្សាស្តីពីរេដបូកចំនួន ៨ ក្នុងចំណោមកម្មវិធីសរុបចំនួន១០ត្រូវបានផលិត និងបានចាក់ផ្សាយ។ ជាមួយគ្នានេះដែល កម្មវិធីវិទ្យុកិច្ចពិភាក្សាអំពីរេដបូកចំនួន ៧ ក្នុងចំណោមកម្មវិធីសរុបចំនួន១៧ ក៏បានផលិត និងចាក់ផ្សព្វផ្សាយផងដែរ។ កម្មវិធីទូរទស្សន៍មានការចូលរួមពីនិស្សិតសកលវិទ្យាល័យស្តាប់ការបកស្រាយពន្យល់ពីវាគ្មិន និងបានសួរសំណួរដេញដោលនៅក្នុងកម្មវិធីផ្ទាល់ផងដែរ។ កម្មវិធីនីមួយៗមានរយៈពេលពី ៣០ ទៅ ៤០ នាទី។ ដោយឡែកកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ជាកម្មវិធីផ្សាយបន្តផ្ទាល់ ដែលផ្តល់ឱកាសឲ្យប្រិយមិត្តអ្នកស្តាប់ទូរស័ព្ទចូលសួរសំណួរ នៅក្នុងកម្មវិធីបាន។ កម្មវិធីនេះមានរយៈពេល ៥០ នាទី។

ប្រធានបទសំខាន់ៗដែលបានផលិតនិងផ្សព្វផ្សាយក្នុងកម្មវិធីទូរទស្សន៍ និងវិទ្យុ រួមមាន អ្វីទៅជារេដបូក សកម្មភាពរេដបូក កម្រិតបំភាយយោង លទ្ធផលនៃការអនុវត្តរេដបូក ការចំណាយ និងផលប្រយោជន៍រេដបូក ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ព្រៃឈើនិងការប្រែប្រួលអាកាសធាតុ ការចែករំលែកផលប្រយោជន៍ពីរេដបូក និងការចូលរួមរបស់សហគមន៍នៅក្នុងការអនុវត្តរេដបូក។ល។

វាគ្មិនអញ្ជើញចូលរួមក្នុងកម្មវិធីនេះរួមមានមន្ត្រីជំនាញមកពីរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការសង្គមស៊ីវិល។ ទូរទស្សន៍ជាតិកម្ពុជា ក៏បានបង្កើនកាលវិភាគផ្សព្វផ្សាយសម្រាប់កម្មវិធីនីមួយៗ ចំនួនពី ២-៣ ដងក្នុងមួយសប្តាហ៍ផងដែរ។

ការផ្តល់ព័ត៌មានត្រលប់ពីសាធារណៈជនបានបង្ហាញថា ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងអំពីរេដបូក គឺជាវិធីដ៏មានប្រសិទ្ធិភាពមួយ ហើយលេខាធិការដ្ឋានរេដបូកកម្ពុជានឹងបន្តប្រើប្រាស់វិធីសាស្ត្រនេះក្នុងឆ្នាំ ខាងមុខបន្តទៀត។ការប្រើប្រាស់វិធីសាស្ត្រនេះ នឹងបន្តផ្សព្វផ្សាយបានទូលំទូលាយដល់សាធារណជនទូទៅ ដែលអាចប្រែក្លាយការយល់ដឹងពីរេដបូក ទៅជាសកម្មភាពអនុវត្តជាក់ស្តែងនៅមូលដ្ឋាន ដើម្បីរួមចំណែកដល់ការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ។

## ការផ្សព្វផ្សាយផែនការប្រចាំប្រទេសនៃកម្មវិធីរេដបូកនៅសហគមន៍

នាខែកុម្ភៈ ឆ្នាំ២០១៥ កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេស ៦ផ្សេងទៀតបានចូលរួមអនុវត្តនិងបានផ្សព្វផ្សាយការចាប់ផ្តើមអនុវត្តសកម្មភាពរេដបូកនៅសហគមន៍តាមរយៈការផ្សព្វផ្សាយអញ្ជើញអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាតិឲ្យដាក់សំណើគម្រោងសុំថវិកាគាំទ្រដល់ការអនុវត្តគម្រោងរេដបូកខ្នាតតូចនៅសហគមន៍នេះ។

ក្នុងដំណាក់កាលសាកល្បងបច្ចុប្បន្ន រេដបូកនៅសហគមន៍ គឺជាគម្រោងផ្តួចផ្តើមជាដៃគូរវាងកម្មវិធី UN-REDD និងកម្មវិធីជំនួយខ្នាតតូចរបស់មូលនិធិបរិស្ថានពិភពលោក (GEF) ដែលផ្តល់ថវិកាគាំទ្រផ្ទាល់រហូតដល់ ៥០០០០ ដុល្លាសហរដ្ឋអាមេរិកដល់ជនជាតិជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ កម្មវិធីរេដបូកនៅសហគមន៍ មានគោលបំណងផ្តល់ភាពអង់អាចឲ្យអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ចូលរួមឲ្យបានពេញលេញ នៅក្នុងការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដានសកម្មភាពត្រៀមលក្ខណៈអនុវត្តរេដបូក ព្រមទាំងរៀបចំចងក្រងបទពិសោធន៍ មេរៀនិងអនុសាសន៍នៅថ្នាក់មូលដ្ឋាន ដែលអាចផ្តល់ជាមតិយោបល់សម្រាប់ដំណើរការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ រេដបូកនៅសហគមន៍ បាននឹងកំពុងអនុវត្តសាកល្បង នៅក្នុងប្រទេសចំនួន ៦ រួមមាន ប្រទេសកម្ពុជា ស្រីលង្កា ប៉ាណាម៉ា ប៉ារ៉ាហ្គាយ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ និងនីហ្សេរីយ៉ា។

តាមរយៈការផ្តល់ការគាំទ្រដល់ការការពារព្រៃឈើ និងការផ្តល់ភាពអង់អាចដល់សហគមន៍ព្រៃឈើ ដែលរស់នៅ និងពឹងអាស្រ័យលើផលព្រៃឈើ រេដបូក



នៅសហគមន៍ មានគោលបំណងរួមចំណែកសម្រេចនូវគោលដៅទូលំទូលាយខាងបរិស្ថាន និងសង្គម រួមនឹងការអភិរក្សជីវចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀង ការលើកកម្ពស់សិទ្ធិនិងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការផ្សព្វផ្សាយដាក់ឲ្យអនុវត្តកម្មវិធីរេដបូកនៅសហគមន៍នៅកម្ពុជាបានធ្វើឡើងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានសម្រាប់រៀបចំផែនការយុទ្ធសាស្ត្ររេដបូកនៅសហគមន៍។ ផែនការដែលត្រូវបានរៀបចំឡើងនៅតាមបណ្តាប្រទេសសាកល្បងនីមួយៗ គឺជាមគ្គុទ្ទេសក៍ណែនាំពីការជ្រើសរើសគម្រោងរេដបូកសហគមន៍ និងធានាយ៉ាងណាឲ្យសកម្មភាពរេដបូក សហគមន៍ស្របទៅតាមដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា។

កន្លងមកនៅកម្ពុជាមានកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ចំនួន ៣ លើកត្រូវបានរៀបចំឡើង នៅតំបន់វាលទំនាបភាគខាងជើងនិងតំបន់ជួរភ្នំដងរែក តំបន់ភាគឦសាន តំបន់ឆ្នេរ និងតំបន់ជួរភ្នំក្រវាញ ដោយមានអ្នកចូលរួមប្រមាណជា១៣៥នាក់ មកពីសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិក្សាស្រាវជ្រាវ។ ប្រធានបទពិគ្រោះយោបល់ថ្នាក់សហគមន៍ចំនួន៣ និងត្រូវបានរៀបចំឡើង ដើម្បីកំណត់ពីតម្រូវការ និង បទពិសោធន៍ជាក់លាក់របស់សហគមន៍ពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ។ កិច្ចពិគ្រោះយោបល់នីមួយៗក្នុងចំណោមកិច្ចពិគ្រោះយោបល់ទាំងនេះមានការចូលរួមពីសមាជិកសហគមន៍ប្រមាណជា២៥នាក់។ បន្ទាប់ពីដំណើរការពិគ្រោះយោបល់បានបញ្ចប់រួចរាល់ សិក្ខាសាលាថ្នាក់ជាតិបានរៀបចំឡើងនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០១៤ ជាមួយតំណាងចំនួន ៥២នាក់ មកពីក្រុមអ្នកពាក់ព័ន្ធ ដែលធ្លាប់ត្រូវបានពិគ្រោះយោបល់កន្លងមកព្រមទាំងមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ជនជាតិដើមភាគតិច និងវិស័យឯកជន។

## ការចែករំលែកមេរៀន និងបទពិសោធន៍ត្បូង-ត្បូង (South-South Sharing) ស្តីពីកម្រិតបំភាយយោងពីព្រៃឈើ

ប្រទេសកំពុងអភិវឌ្ឍន៍ដែលចូលរួមនៅក្នុងដំណាក់កាលត្រៀមលក្ខណៈអនុវត្តរេដបូក ចាំបាច់ត្រូវកសាងសមត្ថភាពជាតិដើម្បីធ្វើការកសាងកម្រិតបំភាយយោងពីព្រៃឈើ (ដែលហៅកាត់ថា FRELs)។ FRELs មានសារសំខាន់សម្រាប់ធ្វើការកំណត់ពីលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេស ក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបង្កើនការស្រូបយកឧស្ម័នផ្ទះកញ្ចក់តាមរយៈកម្មវិធីរេដបូកជាតិ។ នេះគឺជាទស្សនទានថ្មីមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ហេតុដូចនេះមានបញ្ហាប្រឈមផ្នែកសមត្ថភាពជាច្រើន សម្រាប់ប្រទេសដែលមានបំណងចូលរួមនៅក្នុងយន្តការរេដបូក។ ប្រទេសទាំងនេះនឹងទទួលបានអត្ថប្រយោជន៍ច្រើនតាមរយៈការចែករំលែកបទពិសោធន៍របស់ពួកគេមុននឹងដាក់ FRELs ទៅកាន់ UNFCCC។

កម្មវិធី UN-REDD និងគម្រោងFCPF កំពុងព្យាយាមដោះស្រាយបញ្ហាឧបសគ្គ ផ្នែកសមត្ថភាព តាមរយៈការរៀបចំព្រឹត្តិការណ៍ស្តីពីការចែករំលែកមេរៀន និងបទពិសោធន៍ត្បូង-ត្បូង នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលអំពី FRELs និងការបង្កើនចំណេះដឹងដល់អ្នកពាក់ព័ន្ធ។ ផ្នែកមួយនៃគំនិតផ្តួចផ្តើមក្នុងការដោះស្រាយឧបសគ្គផ្នែកសមត្ថភាពនេះ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់មួយ បានរៀបចំឡើងនៅ ថ្ងៃទី៤-៥ ខែឧសភា ឆ្នាំ ២០១៥ សម្រាប់អ្នកជំនាញបច្ចេកទេស និងមន្ត្រីមកពីប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ណេប៉ាល់ និងវៀតណាម។ បច្ចុប្បន្ន ប្រទេសទាំងនេះកំពុងស្ថិតនៅក្នុងដំណើរការរៀបចំ FRELs របស់ខ្លួន ដែលបន្ទាប់មក ត្រូវឆ្លងកាត់ការវាយតម្លៃពីអ្នកជំនាញបច្ចេកទេសមួយក្រុម ដែលបង្កើតឡើងដោយ UNFCCC។




សិក្ខាសាលានេះ បានប្រព្រឹត្តិទៅនៅប្រទេសកម្ពុជា ក្រោមការសម្របសម្រួលរៀបចំដោយកម្មវិធី UN-REDD បានផ្តល់លទ្ធភាពឲ្យអ្នកចូលរួមជាង ៣០នាក់ ទទួលបានព័ត៌មាន ធ្វើបច្ចុប្បន្នភាព និងបញ្ជាក់ឲ្យបានកាន់តែច្បាស់បន្ថែមទៀតអំពីដំណើរការរៀបចំ និងវាយតម្លៃ FRELs។

លោក Vu Tan Phuong ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ មកពីបណ្ឌិតសភាវិទ្យាសាស្ត្រព្រៃឈើវៀតណាមបានលើកឡើងថា "ដំបូន្មានដ៏មានប្រយោជន៍ ដែលយើងបានទទួលពីអ្នកជំនាញបច្ចេកទេសមកពីអង្គការ FAO និងបទពិសោធន៍ ដែលបានចែករំលែករវាងប្រទេសនានានៅអាស៊ី មានសារសំខាន់យ៉ាងខ្លាំង ដើម្បីឲ្យប្រតិភូវៀតណាមអាចកែលំអ FRELs របស់ខ្លួនមុននឹងដាក់ជូន UNFCCC"។ អ្នកចូលរួមពីបណ្តាប្រទេសនានាបានគាំទ្រដល់ការលើកឡើងនេះផងដែរ។ បណ្ឌិត Mohan Poudel លេខាធិការស្តីទីនៃមជ្ឈមណ្ឌលអនុវត្តរេដបូករបស់ប្រទេសណេប៉ាល់បានមានមតិថា "ផ្អែកទៅតាមដំបូន្មាន ដែលយើងបានទទួលពីសិក្ខាសាលានេះ យើងនឹងធ្វើការកែសម្រួលសេចក្តីព្រាង FRELs របស់យើង មុននឹងដាក់ជូន UNFCCC"។ បណ្ឌិត María J. Sanz-Sanchez ប្រធានក្រុមការងារ UN-REDD របស់អង្គការ FAO និងជាអ្នកជំនាញបច្ចេកទេស FRELs បានលើកឡើងថា ប្រទេសជាច្រើនមានក្តីបារម្ភសំខាន់ៗចំនួន ២ដូចគ្នា៖ ទីមួយ តើត្រូវកំណត់ និងវាស់វែងការរេចរឹលព្រៃឈើដោយរបៀបណា? និងទីពីរ ថាតើត្រូវដាក់បញ្ចូលការបង្កើនការស្តុកកាបូនព្រៃឈើទៅក្នុង FRELs របស់ខ្លួនដោយរបៀបណា?។

បទពិសោធន៍ប្រទេសម៉ាឡេស៊ីដែលជាប្រទេសតែមួយគត់នៅអាស៊ី ដែលបានដាក់ជូន FRELs របស់ខ្លួនទៅកាន់ UNFCCC រួចមកហើយនោះ ត្រូវបានអ្នកចូលរួមមកពីប្រទេសផ្សេងទៀតលើកឡើងថា ជាអត្ថប្រយោជន៍ដ៏ធំធេង សម្រាប់ការផ្លាស់ប្តូរបទពិសោធន៍នៅថ្នាក់តំបន់។ ប្រតិភូមកពីប្រទេសម៉ាឡេស៊ី បានផ្តល់នូវដំបូន្មាន និងព័ត៌មានត្រឡប់ផ្ទាល់លើដំណើរការវាយតម្លៃរបស់អ្នកជំនាញ UNFCCC និងមេរៀនដែលពួកគេបានទទួលពីបទពិសោធន៍នេះ។ ប្រទេសចំនួន ៨ ផ្សេងទៀតបានរៀបចំបទបង្ហាញសង្ខេបអំពីចក្ខុវិស័យបច្ចុប្បន្នសម្រាប់ FRELs នៅថ្នាក់ជាតិ ដែលបានឆ្លងកាត់ការវាយតម្លៃពីក្រុមអ្នកជំនាញបច្ចេកទេសដែលមានវត្តមានចូលរួមនៅក្នុងសិក្ខាសាលាផងដែរ។ ប្រតិភូពីប្រទេសឥណ្ឌូណេស៊ី បានលើកឡើងថា "សកម្មភាពដែលយើងបានធ្វើនៅក្នុងសិក្ខាសាលានេះ បានផ្តល់ការបញ្ជាក់សារជាថ្មីឲ្យយើងដឹងថា យើងនឹងមានលទ្ធភាពអាចធ្វើការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះដំណើរការវាយតម្លៃរបស់ UNFCCC"។ ក្នុងនាមជាម្ចាស់ផ្ទះ ប្រទេសកម្ពុជាបានបញ្ជូនប្រតិភូមួយក្រុម ដែលមានមន្ត្រីចំនួន ១២នាក់ទៅចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នេះ។ ពួកគេបានទទួល

ការប្រឹក្សាយោបល់ជាពិសេស ជាមួយអ្នកជំនាញបច្ចេកទេសអំពីសមាសភាគជាក់លាក់ដែលត្រូវពិចារណា នៅពេលដែលប្រទេសកម្ពុជារៀបចំបញ្ចប់ឯកសារ FRELs របស់ខ្លួន។

ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ណេប៉ាល់ និងវៀតណាម គ្រោងនឹងបន្តបំពេញការងារនេះបន្ថែមទៀត ដើម្បីដាក់ជូន FRELs របស់ខ្លួនទៅកាន់ UNFCCC។ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឈានចូលទៅដល់ដំណើរការវាយតម្លៃបច្ចេកទេសពី UNFCCសម្រាប់ឆ្នាំ ២០១៦ប្រទេសនានា រួមទាំងប្រទេសកម្ពុជាត្រូវដាក់ជូនឯកសារ FRELs ឲ្យបានមុនចុងខែធ្នូ ឆ្នាំ២០១៥។

## យុទ្ធសាស្ត្រ ស្តីពីតំបន់ការពារ

ក្រសួងបរិស្ថាន ជាក្រសួងដែលទទួលខុសត្រូវលើប្រព័ន្ធតំបន់ការពារ នៅក្នុងប្រទេសកម្ពុជាដែលមានវិសាលភាពគ្របដណ្តប់លើតំបន់ចំនួន ២៣កន្លែង ដែលមានទំហំស្មើនឹង ៣,៣ លានហិកតា (១៨,៣ ភាគរយនៃផ្ទៃដីសរុប)។ ប្រព័ន្ធតំបន់ការពារនេះមានឧទ្យានជាតិចំនួន ៧ តំបន់អភិរក្សសត្វព្រៃចំនួន ១០ តំបន់ការពារទេសភាពចំនួន ៣ និងតំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣។ តំបន់ការពារទាំងនេះ គ្រប់គ្រងដោយក្របខ័ណ្ឌគោលនយោបាយសំខាន់ៗរួមមាន រដ្ឋធម្មនុញ្ញ (១៩៩៣) ច្បាប់ស្តីពីតំបន់ការពារ (២០០៨) និងច្បាប់ស្តីពីការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ (១៩៩៦)។

ចាប់តាំងពីឆ្នាំ ២០១៤មក ក្រសួងបរិស្ថានបាននឹងកំពុងរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ (NPASMP) សម្រាប់រយៈពេល ១០ឆ្នាំ ដើម្បីពង្រឹងដល់ការអនុវត្តបទបញ្ញត្តិនានាដែលមានស្រាប់ ឲ្យកាន់តែមានប្រសិទ្ធភាព។ ផែនការយុទ្ធសាស្ត្រនេះ នឹងត្រួសត្រាយផ្លូវសម្រាប់ការអនុវត្តគោលយោបាយជាតិស្តីពីតំបន់ការពារឲ្យមានប្រសិទ្ធភាពតាមរយៈការចាត់ជាអាទិភាពយុទ្ធសាស្ត្រ និងអភិក្រមពាក់ព័ន្ធសម្រាប់ការអភិរក្ស និងការគ្រប់គ្រងតំបន់ការពារប្រកបដោយនិរន្តភាព ការពង្រីកឱកាសប្រកបរបរចិញ្ចឹមជីវិតរស់នៅរបស់សហគមន៍ និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័នរបស់ក្រសួង។ ផែនការយុទ្ធសាស្ត្រនេះក៏នឹងបំពេញតួនាទីជាគោលនយោបាយដ៏សំខាន់ សម្រាប់ភ្ជាប់ទំនាក់ទំនងរេដបូកជាមួយនឹងការគ្រប់គ្រងតំបន់ការពារនៅថ្នាក់ជាតិ។

កន្លងមក ជាមួយនឹងការគាំទ្រពីកម្មវិធី UN-REDD និងគម្រោង FCPF ក្រសួងបរិស្ថានបានរៀបចំសេចក្តីព្រាងបឋមនៃផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ សម្រាប់ដាក់ឲ្យពិភាក្សា ។ សេចក្តីព្រាងផែនការនេះ បានរៀបចំផ្អែកទៅតាមលទ្ធផលនៃការ វាយតម្លៃលើស្ថានភាពបច្ចុប្បន្ន និងអភិក្រមគ្រប់គ្រងតំបន់ការពារ ព្រមទាំងផ្អែកលើលទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ការវិភាគលើការចំណាយ និងផលប្រយោជន៍នៃការអនុវត្តរេដបូក

នៅក្នុងសិក្ខាសាលាស្តីពីការវិភាគលើការចំណាយ និងផលប្រយោជន៍ នៃការអនុវត្តរេដបូក ឯកឧត្តមបណ្ឌិត ជា សំអាង ប្រធានកម្មវិធីរេដបូកជាតិ បានមានប្រសាសន៍ថា សិក្ខាសាលានេះគឺជាព្រឹត្តិការណ៍ដ៏ពិសេសមួយ ដែលជួយឲ្យអ្នកចូលរួមបានយល់ដឹងពីសក្តានុពលនៃផលប្រយោជន៍ ដែលទទួលបានពីសកម្មភាពរេដបូក និងពីបញ្ហានានាពាក់ព័ន្ធនឹងការវិភាគលើការចំណាយ និងផលប្រយោជន៍នៃការអនុវត្តរេដបូកនៅកម្ពុជា។ ផលប្រយោជន៍រេដបូករួមមានផលប្រយោជន៍ ពាក់ព័ន្ធនឹងការទូទាត់ សម្រាប់ការកាត់បន្ថយការបំភាយឧស្ម័ន ក៏ដូចជាសក្តានុពលផលប្រយោជន៍ដទៃទៀតដូចជាការលើកកម្ពស់ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិជាដើម។



សិក្ខាសាលាដ៏មានសារសំខាន់នេះមានសិក្ខាកាមចូលរួមជាង ៣០នាក់ មកពីក្រុមការងាររេដបូក រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ លេខាធិការដ្ឋានរេដបូក និងក្រុមប្រឹក្សាយោបល់រេដបូក។ នេះសបញ្ជាក់ថាគឺជាផ្នែកមួយនៃគម្រោង ដែលផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីរេដបូក នៅកម្ពុជាតាមរយៈការជួយរៀបចំ និងសាកល្បងវិភាគលើការចំណាយ ផលប្រយោជន៍ និងការវិភាគ spatial ដែលនឹងត្រូវអនុវត្តសកម្មភាពរេដបូក។ ជាទូទៅ ការចំណាយរេដបូករួមមានការចំណាយឱកាស ការចំណាយសម្រាប់ការអនុវត្ត ការងារប្រតិបត្តិការងាររដ្ឋបាល និងការចំណាយធ្វើឲ្យមានស្ថិរភាពនិងការចំណាយសង្គម។ការចំណាយឱកាស សំដៅលើការបាត់បង់ប្រយោជន៍មួយចំនួន ដូចជាការអភិរក្សព្រៃឈើក្រោមយន្តការរេដបូកជំនួសឲ្យដោយផលប្រយោជន៍ផ្សេងដែលអាចទទួលបាន ប្រសិនបើគេយកដីនេះទៅប្រើប្រាស់សម្រាប់សកម្មភាពផ្សេង ជំនួសឲ្យការរក្សាទុកជាដីព្រៃឈើ។ភាពខុសប្លែកគ្នារវាងផលប្រយោជន៍ដែលព្រៃឈើផ្តល់ឲ្យ និងផលប្រយោជន៍ដែលទទួលបានពីជម្រើសផ្សេងទៀតគឺជាចំណាយឱកាសសម្រាប់ធ្វើការពិចារណាបញ្ចៀសមិនឲ្យមាន ការបាត់បង់ព្រៃឈើ។ តាមរយៈការធ្វើការងារជាក្រុម និងការពិភាក្សា អ្នកចូលរួមបានលើកឡើងនូវអនុសាសន៍ដើម្បីកែសម្រួលតារាងវិភាគ និងបានលើកឡើងពីបញ្ហាប្រឈមជាច្រើនដូចជាការគណនាបម្លែងការចំណាយ និងផលប្រយោជន៍ដែលទទួលបានទៅជាគុណតម្លៃក្នុងមួយហិកតាជាដើម។

ជាងនេះទៅទៀត អនុសាសន៍សំខាន់ៗ សម្រាប់តម្រង់ទិសដល់ការកែសម្រួលតារាងបន្តរួមមានទិន្នន័យបន្ថែមពីកិច្ចការជាក់លាក់ និងការចំណាយនានា គួរប្រមូលពីស្ថាប័នពាក់ព័ន្ធឲ្យបានច្រើនតាមដែលអាចធ្វើបាន ជាពិសេសការចំណាយដែលពាក់ព័ន្ធកិច្ចការជាក់លាក់ គួររៀបរាប់ឲ្យបានលំអិតជាងនេះ ដូចជាព័ត៌មានយោង និងទិន្នន័យនៅក្នុងតារាង ដែលត្រូវធ្វើបច្ចុប្បន្នភាពបន្ថែមទៀតដើម្បីឲ្យមានលក្ខណៈគ្រប់គ្រាន់អាចគណនាចំណាយសម្រាប់កិច្ចការជាក់លាក់មួយចំនួនទៀតបានក្នុងមួយហិកតា។ ប៉ុន្តែការចំណាយផ្សេងទៀតមិនអាចគណនាបែបនេះបានឡើយ ការគណនាលើការចំណាយនានាគួរពិចារណាលើតម្រូវការរចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងផ្សេងៗគ្នា ហើយគួរមានការបញ្ជាក់ឲ្យបានច្បាស់លាស់បន្ថែមទៀតពីវិធីសាស្ត្រសម្រាប់ធ្វើការគណនា។

## ការរៀបចំប្រព័ន្ធធានាសុវត្ថិភាពសម្រាប់កម្មវិធីរេដបូក នៅកម្ពុជា

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំប្រព័ន្ធធានាសុវត្ថិភាពសម្រាប់កម្មវិធី រេដបូកជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង ដើម្បីរៀបចំអភិក្រមជាតិសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថានសម្រាប់រេដបូកនៅកម្ពុជា។ ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដបូក បានរៀបចំកិច្ចពិគ្រោះយោបល់ចំនួន ៤ លើក នៅថ្នាក់ក្រោមជាតិ ចាប់តាំងពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤។ កិច្ចប្រជុំទាំងនេះ ត្រូវបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ នៅស្នាក់ការអធិការដ្ឋានរដ្ឋបាលព្រៃឈើទូទាំងប្រទេស។ កិច្ចប្រជុំពិគ្រោះយោបល់នេះ ត្រូវបានធ្វើឡើង នៅខេត្តក្រចេះ សម្រាប់អធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ ខេត្តសៀមរាបសម្រាប់អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប ខេត្តពោធិ៍សាត់សម្រាប់អធិការដ្ឋានរដ្ឋបាលព្រៃឈើ ខាងត្បូងបឹងទន្លេសាប និងខេត្តព្រះសីហនុសម្រាប់អធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រ។

កិច្ចប្រជុំថ្នាក់ក្រោមជាតិទាំង ៤ លើកនេះ មានអ្នកចូលរួមមកពី ២២ ខេត្ត ក្រុង និងរាជធានី។ សិក្ខាកាម ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពីតាមបណ្តាខេត្តនីមួយៗ រួមមាន តំណាងមកពីស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា (រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន រដ្ឋបាលជលផល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងរ៉ែ និងថាមពល) អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចៗ ក្នុងករណីនេះកិច្ចប្រជុំនៅខេត្តក្រចេះមានសិក្ខាកាមចូលរួម៥៥នាក់ខេត្តសៀមរាប៦៩នាក់ខេត្តពោធិសាត់ ៦១នាក់ និងខេត្តព្រះសីហនុ ៦៤នាក់។

កិច្ចប្រជុំទាំង ៤ មានសិក្ខាកាមសរុបចូលរួម ២៤៩នាក់។ លទ្ធផលគួរឲ្យកត់សំគាល់ដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់នេះរួមមាន (១) ការបង្កើនការយល់ដឹងរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋានស្តីពីរេដបូក និងវឌ្ឍភាពរេដបូកនៅកម្ពុជា និងអន្តរជាតិ ព្រមទាំងហានិភ័យខាងសង្គម និងបរិស្ថាន ដែលអាចកើតមានឡើងពីការអនុវត្តរេដបូក និងសេចក្តីសម្រេចរបស់ UNFCCC ស្តីពីការធានាសុវត្ថិភាពរេដបូក និងហានិភ័យដែលកើតចេញពីកម្មវិធី UN-REDD និងគម្រោង FCPF របស់ធនាគារពិភពលោក (២) មិតយោបល់របស់អ្នក



ពាក់ព័ន្ធនៅមូលដ្ឋានលើហានិភ័យផ្នែកសង្គម និងបរិស្ថាន ដែលអាចកើតមានឡើងនៅក្នុងតំបន់របស់ពួកគាត់ ប្រសិនមានការអនុវត្តសកម្មភាពរេដបូក និង (៣) មិតយោបល់របស់អ្នកពាក់ព័ន្ធនៅមូលដ្ឋានអំពីជម្រើសនានា ដែលអាចមាន ដើម្បីឆ្លើយតប ចំពោះហានិភ័យដែលបានរកឃើញ។ លទ្ធផលដែលទទួលបានពីកិច្ចប្រជុំទាំងនេះ នឹងប្រើប្រាស់ជាមតិយោបល់ និងអនុសាសន៍ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិ ដែលនឹងមានការលើកស្នើឡើង នូវសេចក្តីព្រាងអភិក្រមជាតិសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន សម្រាប់រេដបូកនៅកម្ពុជា។

## កិច្ចប្រជុំលើកទី ៦ របស់ក្រុមការងាររេដបូកកម្ពុជា

កិច្ចប្រជុំលើកទី៦ ក្រុមការងាររេដបូកកម្ពុជាបានប្រព្រឹត្តិទៅនាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ នៅខេត្តកែប ដែលមានសមាជិកចូលរួមចំនួន៣៥នាក់មកពីក្រុមការងាររេដបូក ក្រុមបច្ចេកទេសរេដបូកមន្ត្រីលេខាធិការដ្ឋានរេដបូក និងទីប្រឹក្សាគម្រោងបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។

សមាជិកក្រុមការងាររេដបូកកម្ពុជាមានតំណាងមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែ និងថាមពល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការសង្គមស៊ីវិល ។ ការរៀបចំរចនាសម្ព័ន្ធស្ថាប័ននេះមានសារសំខាន់ណាស់ ដើម្បីធានាឲ្យមានការចូលរួមពេញលេញ ពីក្រសួងពាក់ព័ន្ធ ដែលកំពុងចូលរួមក្នុងការអនុវត្តសកម្មភាពរេដបូក ។

ឯកឧត្តម ជា សំអាង ប្រធានក្រុមការងាររេដបូកកម្ពុជាបានមានប្រសាសន៍ក្នុងពិធីបើកអង្គប្រជុំដោយបានគូសបញ្ជាក់ថា "កិច្ចប្រជុំលើកទី ៦នេះ មានសារសំខាន់យ៉ាងខ្លាំង ចំពោះការអនុវត្តសកម្មភាពរេដបូក ដោយសារកិច្ចប្រជុំលើកនេះ គឺជាវេទិកាមួយដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ២០១៤ ព្រមទាំងការពិភាក្សា និងការពិគ្រោះយោបល់លើផែនការសកម្មជាក់លាក់សម្រាប់ឆ្នាំ ២០១៥ សំដៅអនុវត្តសកម្មភាពរេដបូកឲ្យស្របទៅតាមកម្មវិធីអភិវឌ្ឍន៍ជាតិ" ។

ចាប់តាំងពីឆ្នាំ ២០១៣ ក្រុមការងាររេដបូកកម្ពុជាបានបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការគ្រប់គ្រង និងការសម្របសម្រួលដំណើរការអនុវត្តយុទ្ធសាស្ត្រ និងគម្រោងនានា។ ក្រុមការងាររេដបូកបានធ្វើសេចក្តីសម្រេចអំពីការអនុវត្តគម្រោងសាកល្បង ពិនិត្យតាមដានលើលទ្ធផលគម្រោង ដើម្បីធានាយ៉ាងណាឲ្យលទ្ធផលទាំងនេះស្របទៅតាមបរិបទបច្ចុប្បន្នរបស់ប្រទេសកម្ពុជា និងរាយការណ៍បច្ចុប្បន្នភាពព័ត៌មានចុងក្រោយជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

<u>**កិច្ចប្រជុំបានសម្រេចលទ្ធផលគួរឲ្យកត់សម្គាល់រួមមាន៖**</u>

- ចាត់តាំងលេខាធិការដ្ឋានរេដបូកកម្ពុជាសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធរៀបចំឯកសារសំណើរគម្រោងដើម្បីអនុវត្តសកម្មភាពរេដបូកសាកល្បងថ្នាក់ក្រោមជាតិ
- បង្ហាញ និងអនុម័តលើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ ក្រុមការងាររេដបូក បានរៀបចំ នូវក្របខ័ណ្ឌពេលវេលាច្បាស់លាស់ ដើម្បីរៀបចំកសាងបញ្ចប់យុទ្ធសាស្ត្ររេដបូកជាតិ នៅមុនសន្និសិទនៃបណ្តារដ្ឋភាគីលើកទី២១ (COP21) នៅទីក្រុងប៉ារីស
- ក្រុមការងារយេនឌ័ររេដបូកនឹងត្រូវអញ្ជើញចូលរួម និងចែករំលែកព័ត៌មានអំពីវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រ ទៅក្នុងសកម្មភាពរេដបូក ជាពិសេសនៅក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិនៅក្នុងកិច្ចប្រជុំក្រុមការងាររេដបូកលើកក្រោយ

- អនុញ្ញាតសម្រេចឲ្យដំណើរការសិក្សាលើការបែងចែកផលប្រយោជន៍ពីរេដបូក និងដាក់បញ្ចូលលទ្ធផលនៃការសិក្សាទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ
- ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV)រៀបចំកសាងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក (SIS) ឲ្យស្របទៅតាមផែនការការងារប្រចាំឆ្នាំ ២០១៥។

### ការកសាងសមត្ថភាពក្រុមការងារបច្ចេកទេសរេដបូក និងមន្ត្រីស្ថាប័នពាក់ព័ន្ធថ្នាក់ក្រោមជាតិ

ការកសាងសមត្ថភាពសម្រាប់មន្ត្រីរដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ និងរដ្ឋបាលជលផលត្រូវបានធ្វើឡើង ដោយមានការឧបត្ថម្ភថវិកាពីគម្រោង FCPF។ ទោះបីយ៉ាងនេះក្តី វិសាលភាព និងប្រពលភាពនៃការកសាងសមត្ថភាពចាំបាច់ត្រូវពង្រីកបន្ថែមទៀត ទាំងការកសាងសមត្ថភាពនៅកម្រិតបុគ្គល និងកម្រិតស្ថាប័ន។

នាចុងឆ្នាំ ២០១៤ សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិ ត្រូវបានរៀបចំធ្វើឡើងនៅរាជធានីភ្នំពេញ ក្នុងគោលបំណងអភិវឌ្ឍសមត្ថភាពមន្ត្រីចំនួន ៤១នាក់ មកពីរដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ និងរដ្ឋបាលជលផល អំពីការអនុវត្តកម្មវិធីរេដបូកជាតិ។ សិក្ខាសាលាបណ្តុះបណ្តាលនេះ បានផ្តោតការយកចិត្តទុកដាក់លើក្របខ័ណ្ឌ Warsaw និងការពាក់ព័ន្ធចំពោះការអនុវត្តរេដបូកនៅកម្ពុជា ការពិនិត្យតាមដានព្រៃឈើ និងប្រព័ន្ធធានាសុវត្ថិភាពរេដបូក។

វគ្គបណ្តុះបណ្តាលចំនួន ៤ វគ្គបានរៀបចំឡើងបានទទួលជោគជ័យ ជាអាទិ៍ នៅខេត្តបាត់ដំបង សៀមរាប ក្រចេះ និងព្រះសីហនុ ដែលមានអ្នកចូលរួមចំនួន ២១៧នាក់ មកពីអធិការដ្ឋានរដ្ឋបាលព្រៃឈើ ខណ្ឌ និងសង្កាត់រដ្ឋបាលព្រៃឈើ មន្ត្រីឧទ្យានជាតិ ដែនជម្រកសត្វព្រៃ និងខណ្ឌរដ្ឋបាលជលផល។ សិក្ខាកាមទាំងអស់ បានទទួលចំណេះដឹងជាច្រើនស្តីពីរេដបូក ពិសេសលើចលករដែលនាំឲ្យមានការបាត់បង់ និងការរេចរឹលព្រៃឈើ គោលនយោបាយ និងវិធានការដើម្បីកាត់បន្ថយការបំភាយឧស្ម័ន តាមរយៈការតាមដាន ការរាយការណ៍ និងការផ្ទៀងផ្ទាត់ ការពិនិត្យតាមដាន ការបែងចែកផលប្រយោជន៍ ការធានាសុវត្ថិភាព ក៏ដូចជា ការព្រមព្រៀងដោយសេរីជាមុន និងព័ត៌មានគ្រប់គ្រាន់ (FPIC)និងវឌ្ឍនភាពនៃការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា រួមទាំងការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។



សិក្ខាសាលាបណ្តុះបណ្តាលនេះ ក៏បានផ្តល់ឱកាសឲ្យអ្នកចូលរួមធ្វើការពិភាក្សា លើប្រធានបទចំនួន ២ ដូចខាងក្រោម ៖

ប្រធានបទទី១៖ ផ្តោតលើរបៀបដែលកម្មវិធីរេដបូកកម្ពុជាអាចផ្តល់ការកសាងសមត្ថភាពក្រុមការងារបច្ចេកទេស និងមន្ត្រីតាមស្ថាប័នពាក់ព័ន្ធ និងរបៀបពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តសកម្មភាពរេដបូកប្រកបដោយជោគជ័យនៅកម្ពុជា។

- ផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោល (ToT) ដល់មន្ត្រីតាមស្ថាប័នពាក់ព័ន្ធ អំពីយន្តការអនុវត្តរេដបូក ជំនាញសម្របសម្រួល បញ្ហាបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍរេដបូក ដូចជាវិធីសាស្ត្រ សម្រាប់គណនាការស្រូប និងការបំភាយកាបូន
- ដំណើរទស្សនៈកិច្ចសិក្សាក្នុងប្រទេស និងតំបន់ទៅតាមបណ្តាប្រទេសនានា ដែលមានគំរូ និងបទពិសោធន៍ល្អៗ ពាក់ព័ន្ធនឹងការអនុវត្តរេដបូក
- ផ្តល់ការគាំទ្រដល់ក្រុមផ្សព្វផ្សាយនូវឧបករណ៍ និងបរិក្ខារផ្សេងៗសម្រាប់ផ្សព្វផ្សាយបង្កើនការយល់ដឹងស្តីពីរេដបូក
- ផ្តល់ការបណ្តុះបណ្តាល តាមរយៈការអនុវត្តការងារជាក់ស្តែង ជាមួយនឹងអ្នកជំនាញបច្ចេកទេសជាតិ និងអន្តរជាតិ និងបង្កើនការយល់ដឹងអំពីសារសំខាន់របស់រេដបូក។

ប្រធានបទពិភាក្សាទី ២៖ ផ្តោតលើតម្រូវការ សម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអភិវឌ្ឍរេដបូកនៅកម្ពុជាសម្រាប់ការបណ្តុះបណ្តាល ដល់មន្ត្រីនៅថ្នាក់ក្រោមជាតិ។

ព័ត៌មានត្រឡប់ ដែលទទួលបានពីការពិភាក្សា និងសំណូមពរនានា លៃលើកឡើងដោយសិក្ខាកាមរួមមាន ៖

- ផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រី នៅតាមខណ្ឌរដ្ឋបាលនីមួយៗ និងមន្ត្រីនៅថ្នាក់នាយកដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ។ មន្ត្រីដែលបាននឹងកំពុងបំពេញការងារនៅឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ គួរទទួលបានការបណ្តុះបណ្តាលលើប្រធានបទជាក់លាក់មួយចំនួន ដើម្បីបង្កើនការយល់ដឹងពីយន្តការរេដបូក វិធីសាស្ត្រសម្រាប់ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ និងជំនាញសម្រាប់ការគ្រប់គ្រង។
- បង្កើនការយល់ដឹងអំពីរេដបូក និងគោលនយោបាយរបស់រដ្ឋាភិបាល ដែលគាំទ្រដល់ការអនុវត្តរេដបូកនៅតាមស្ថាប័ន ជាពិសេស នៅតាមសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិនៅតាមទីតាំងពាក់ព័ន្ធ។

## បង្កើនការយល់ដឹងអំពីសកម្មភាពរេដបូកតាមសាលារៀន

ផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តការផ្សព្វផ្សាយបង្កើនការយល់ដឹង អំពីរេដបូកដល់គ្រប់ភាគីពាក់ព័ន្ធកម្មវិធីរេដបូកកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃដោយមានការគាំទ្រថវិកាពីកម្មវិធី UN-REDD និងគម្រោង FCPF បានអនុវត្តសកម្មភាពផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សិស្សនៃសាលាបឋមសិក្សា និងសាលាមធ្យមសិក្សា នៅជុំវិញសហគមន៍ព្រៃឈើ នៅខេត្តសៀមរាប។

ក្រុមការងារផ្សព្វផ្សាយ បានចុះជួបជាមួយនឹងលោកគ្រូ អ្នកគ្រូ នៅក្នុងភូមិចំនួន ៥ភូមិ ដើម្បីផ្តល់និងពន្យល់ពីឯកសារដែលត្រូវយកមកប្រើប្រាស់ និងរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយបង្កើនការយល់ដឹង។ សកម្មភាពផ្សព្វផ្សាយនេះ បានរៀបចំឡើងនៅតាមសាលារៀននីមួយៗ។

ឯកសារ និងសម្ភារៈប្រើប្រាស់ក្នុងសកម្មភាពផ្សព្វផ្សាយ រួមមានខិតប័ណ្ណផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ ខ្មៅដៃចំរុះពណ៌ ជ័រលុប សៀវភៅកត់ត្រា និងក្រដាសសម្រាប់គូររូបទំហំ A3 ត្រូវបានផ្តល់ឲ្យសិស្សានុសិស្ស។

មាតាបិតា និងសមាជិកសហគមន៍ព្រៃឈើជុំវិញសាលារៀន ក៏មានវត្តមាននៅក្នុងពិធីផ្សព្វផ្សាយនោះផងដែរ ។

លោកគ្រូ អ្នកគ្រូ បានពន្យល់ពីឯកសារអំណានទៅកាន់សិស្សានុសិស្ស ហើយបន្ទាប់មកពួកគេទស្សនាវីដេអូ ដែលផ្តល់ដោយលេខាធិការដ្ឋានក្រុមការងាររេដបូកអំពីការប្រែប្រួលអាកាសធាតុ និងរេដបូក។ សកម្មភាពផ្សព្វផ្សាយនេះ បានប្រើប្រាស់ម៉ាស៊ីនចាក់ស៊ីឌី និងអគ្គិសនី ដើម្បីបង្ហាញវីដេអូ។ ក្រោយពីទស្សនាវីដេអូ ក៏មានវគ្គសំណួរ និងចម្លើយផងដែរ។ ដើម្បីលើកទឹកចិត្ត ឲ្យសិស្សានុសិស្សកម្រិតបឋមចូលរួមបានផុសផុល ក្រុមការងារ បានរៀបចំរង្វាន់ទឹកដោះគោកញ្ចប់ ចែកទៅឲ្យសិស្សានុស្សិស្ស ដែលលើកដៃឆ្លើយសំណួរបានត្រឹមត្រូវ។

បន្ទាប់មក សិស្សានុសិស្សចូលរួម ត្រូវបានបែងចែកជាក្រុមៗ ដើម្បីពិភាក្សា និងគូរគំនូរ ឆ្លើយតបទៅនឹងសំណួរខាងក្រោម៖

- តើកត្តាអ្វីខ្លះ ដែលនាំឲ្យ ឬរួមចំណែកនាំឲ្យមានការប្រែប្រួលអាកាសធាតុ?
- តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អ្វីខ្លះ?
- តើគេអាចធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ?

អ្នកភូមិម្នាក់មកពីភូមិអូរ ដែលមកជាមួយកូនរបស់គាត់ បានលើកឡើងពីការព្រួយបារម្ភថា បើទោះបីជាអ្នកភូមិរបស់គាត់ បានការពារតំបន់ព្រៃនៅក្នុងភូមិរបស់គាត់ប្រកបដោយប្រសិទ្ធភាពក៏ដោយ ការបំផ្លាញ និងការកាប់ឈើខុសច្បាប់ អាចប្តូរទៅកាន់តំបន់ផ្សេងទៀត ដែលជាកត្តានៅតែបន្តនាំឲ្យមានការបាត់បង់ព្រៃឈើ។ ជាការឆ្លើយតប ក្រុមការងារបានគូសបញ្ជាក់ពីភាពចាំបាច់នៃការសហការប្រឹងប្រែងរួមគ្នាដើម្បីការពារព្រៃឈើ។

នៅតាមសាលារៀនមួយចំនួន កុមារមានការខ្មាសអៀនខ្លាំង ដោយសារតែនេះជាព្រឹត្តិការណ៍លើកទី ១ ដែលពួកគេចូលរួមនៅក្នុងសកម្មភាព ដែលមានសួរជាសំណួរ និងចម្លើយ។ លោកគ្រូ អ្នកគ្រូ និងមាតាបិតាមួយចំនួនបានស្នើឲ្យមានការរៀបចំសកម្មភាពស្រដៀងគ្នានាពេលអនាគត ដោយសារតែសកម្មភាពនេះបានផ្តល់នូវចំណេះដឹងនិងភាពរីករាយដល់សិស្សានុសិស្ស។ មាតាបិតាខ្លះបានលើកឡើងថា ពួកគេនឹងយកអ្វីដែល បានរៀនសូត្រ ទៅចែករំលែកជាមួយអ្នកភូមិ និងមិត្តភ័ក្តិបន្ត។

លោកគ្រូ អ្នកគ្រូនៃសាលារៀនទាំងនោះ មានមោទនភាពចំពោះគំនូរ ដែលគូរដោយសិស្សានុសិស្សរបស់គាត់ ហើយមានផែនការចងក្រងគំនូរទាំងនេះទៅជាសៀវភៅ ដែលនឹងចែកទៅឲ្យសាលារៀនវិញ។

## ជ្រុងមួយនៃមតិអង្គការមិនមែនរដ្ឋាភិបាលលើដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា

តាមរយៈបទសម្ភាសន៍ជាមួយ លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោម៖

សំណួរទី ១

តើលោកគិតថា អ្វីខ្លះដែលជាចំណុចខ្លាំងជាងគេនៃដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូក នៅកម្ពុជាកន្លងមក? តើលោកគិតថា កម្ពុជាអាចចែករំលែកបទពិសោធន៍អ្វីខ្លះទៅឲ្យប្រទេសផ្សេងទៀតបាន អំពីការត្រៀមលក្ខណៈអនុវត្តរេដបូក?

ប្រទេសកម្ពុជា បានទទួលថវិកាពីកម្មវិធី UN-REDD និង គម្រោង FCPF ដើម្បីរៀបចំឯកសារគោលនយោបាយសម្រាប់អនុវត្តរេដបូកនៅកម្ពុជា។ កម្មវិធីរេដបូកកម្ពុជាមានរចនាសម្ព័ន្ធស្ថាប័ន ដោយមានការចូលរួមច្រើនស្ថាប័នរដ្ឋាភិបាល។

រចនាសម្ព័ន្ធនេះមានក្រុមប្រឹក្សាយោបល់រេដបូកចូលរួមផ្តល់យោបល់ដល់ក្រុមការងាររេដបូក អំពីដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូក និងជាវេទិកា សម្រាប់ផ្តល់មតិតំណាងឲ្យអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋានជាពិសេសសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាល។ សមាជិកក្រុមប្រឹក្សាយោបល់រួមមានតំណាង អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ជនជាតិដើមភាគតិច គ្រឹះស្ថានសិក្សាស្រាវជ្រាវ សហគមន៍ និងវិស័យឯកជន។ អង្គការសង្គមស៊ីវិល ចូលរួមនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការពិនិត្យតាមដាន និងការអនុវត្តការគ្រប់គ្រងព្រៃឈើ និងកម្មវិធីរេដបូក។ អង្គការសង្គមស៊ីវិលបានចូលរួមនៅក្នុងរេដបូក ចាប់តាំងពីចាប់ផ្តើមដំណើរការរៀបចំផែនទីបង្ហាញផ្លូវរេដបូក ដែលជាមគ្គុទ្ទេសក៍សម្រាប់អនុវត្តសកម្មភាពរេដបូកនៅកម្ពុជា។




### សំណួរទី ២

### តើអ្វីជាបញ្ហាប្រឈមដែលនៅសេសសល់? តើយើងចាំបាច់ត្រូវធ្វើអ្វីបន្ថែមទៀត ដើម្បីកែលំអដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា?

យុទ្ធសាស្ត្ររេដបូកជាតិ និងក្របខ័ណ្ឌអនុវត្តនៅមិនទាន់ត្រូវបានរៀបចំបញ្ចប់នៅឡើយ។ ជាមួយគ្នានេះដែរ គោលការណ៍ណែនាំជាតិស្តីពីប្រព័ន្ធធានាសុវត្ថិភាព និងការទទួលបានព័ត៌មានដោយសេរី ជាមុន និងដោយមានការយល់ព្រម ក៏នៅមិនទាន់បានរៀបចំរួចរាល់នៅឡើយ។ កន្លងមក មានសកម្មភាពបង្កើនការយល់ដឹង និងកសាងសមត្ថភាពដល់ភាគីពាក់ព័ន្ធមួយចំនួនអំពីទស្សនទានរេដបូកបានរៀបចំឡើង ប៉ុន្តែសមត្ថភាពអ្នកពាក់ព័ន្ធ ដើម្បីយល់ដឹងពីរេដបូក នៅមានកម្រិតនៅឡើយ ហើយការបង្កើនការយល់ដឹងអាចបានជ្រួតជ្រាបទៅដល់ប្រជាជនតែមួយក្រុមតូចប៉ុណ្ណោះ។ ឯកសារបង្កើនការយល់ដឹងអំពីរេដបូក ជាភាសាខ្មែរ នៅមិនទាន់មានគ្រប់គ្រាន់សម្រាប់ចែកជូនផ្សព្វផ្សាយនៅឡើយ។

ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងយន្តការពាក់ព័ន្ធដទៃទៀត ដូចជា ប្រព័ន្ធធានាសុវត្ថិភាព ជម្រើសបែងចែកផលប្រយោជន៍ ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ ។ល។ ដើម្បីឲ្យប្រទេសកម្ពុជាអាចត្រៀមលក្ខណៈរួចរាល់ សម្រាប់ការអនុវត្តរេដបូកនាពេលអនាគតបាន។ ក៏ប៉ុន្តែ នៅមូលដ្ឋានផ្ទាល់ នៅមានការគាំទ្រតិចតួចនៅឡើយ ដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ព្រៃឈើ និងការពារការបំលែងព្រៃធម្មជាតិទៅជាចំការ និងទម្រង់នៃការប្រើប្រាស់ដីធ្លីផ្សេងទៀត។

ដូច្នេះខ្ញុំគិតថា យើងគួរពិចារណាលើចំណុចមួយចំនួនដូចតទៅ៖

- ខណៈពេលដែលកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងគោលនយោបាយដទៃទៀត គួរមានការគាំទ្រដល់ការអនុវត្តសកម្មភាពនៅនឹងមូលដ្ឋានផ្ទាល់ ដើម្បីការពារព្រៃធម្មជាតិ ដូចជាការពង្រឹងការអនុវត្តច្បាប់ ការល្បាត ការដោះស្រាយបញ្ហាកាប់ឈើខុសច្បាប់ និងការបង្កើតសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិជាដើម។
- កសាងសមត្ថភាពភាគីពាក់ព័ន្ធ ជាពិសេស ក្រុមប្រឹក្សាយោបល់រេដបូក ដើម្បីឲ្យពួកគេអាចផ្តល់យោបល់ប្រកបដោយប្រសិទ្ធភាពដល់ក្រុមការងាររេដបូកកម្ពុជាបាន។

- ពន្លឿនការផ្តល់ការគាំទ្រដល់ការបង្កើតសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងការរៀបចំផែនការគ្រប់គ្រងសហគមន៍ដែលជាយន្តការប្រកបដោយសក្តានុពល សម្រាប់អនុវត្ត និងគ្រប់គ្រងរេដបូក។
- កសាងទំនាក់ទំនងល្អរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលដើម្បីពង្រឹងការអនុវត្តច្បាប់។
- ឆ្លើយតបចំពោះតម្រូវការសហគមន៍មូលដ្ឋាន ដើម្បីការពារផលប៉ះពាល់ដែលកើតឡើង ដោយសារការបាត់បង់ទីលំនៅរបស់សហគមន៍ និងការបំលែងដីព្រៃធម្មជាតិ។
- ការពិគ្រោះយោបល់ឲ្យបានទូលំទូលាយជាមួយនឹងអង្គការសង្គមស៊ីវិល ជាពិសេសជាមួយសហគមន៍ពឹងអាស្រ័យលើព្រៃឈើ ជុំវិញគោលនយោបាយពាក់ព័ន្ធ ដូចជា យុទ្ធសាស្ត្ររេដបូកជាតិ ការធានាសុវត្ថិភាពរេដបូក និងការបែងចែកផលប្រយោជន៍ពីរេដបូកជាដើម ដោយសារតែកម្ពុជាគឺជាសមាជិករបស់ UNFCCC។ UNFCCC បានដាក់ចេញនូវគោលការណ៍ ស្តីពីប្រព័ន្ធធានាសុវត្ថិភាពចំនួន ៧ ចំណុច ដែលប្រទេសកម្ពុជាគួរដាក់បញ្ចូលទៅក្នុងដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូក។ គោលការណ៍ទាំងនេះ រួមមាន តម្លាភាព និងប្រសិទ្ធភាពនៃរចនាសម្ព័ន្ធអភិបាលកិច្ចព្រៃឈើជាតិ ការគោរពចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន និងការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីសំណាក់អ្នកពាក់ព័ន្ធ ជាពិសេស ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

### សំណួរទី ៣

បច្ចុប្បន្ន កម្ពុជាកំពុងត្រៀមខ្លួនចាប់ផ្តើមអនុវត្តរេដបូក តើលោកគិតថាអ្វីខ្លះគឺជាជាអាទិភាព សម្រាប់ការចាប់ផ្តើមអនុវត្តរេដបូក?

១. ពន្លឿនការរៀបចំបញ្ចប់ និងអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ប្រព័ន្ធធានាសុវត្ថិភាព និងគោលការណ៍ណែនាំស្តីពី FPIC ដោយធ្វើការពិគ្រោះយោបល់ឲ្យបានទូលំទូលាយ ជាមួយនឹងអ្នកពាក់ព័ន្ធ ជាពិសេសជាមួយអង្គការសង្គមស៊ីវិល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

២. កសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលនិងសហគមន៍មូលដ្ឋានរួមនឹងអាជ្ញាធរមូលដ្ឋាន។ ផ្តល់ការគាំទ្រដល់សមាជិក ក្រុមប្រឹក្សាយោបល់ទាំងលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីពង្រឹងការបំពេញមុខងាររបស់ក្រុមអោយមានប្រសិទ្ធភាព។

៣. គួរមានការកំណត់គោលនយោបាយច្បាស់លាស់ អំពីប្រព័ន្ធធានាសុវត្ថិភាព និងការបែងចែកប្រយោជន៍ និងយន្តការបណ្តឹងត៉វ៉ាដោយមានការពិគ្រោះយោបល់ពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

៤. ពង្រឹងការប្រាស្រ័យទាក់ទង និងការផ្តល់ព័ត៌មានរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ដើម្បីបញ្ចៀសមិនឲ្យមានគម្លាតនៅក្នុងការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពពីភាគីពាក់ព័ន្ធ នៅក្នុងការអនុវត្ត និងពិគ្រោះយោបល់លើដំណើរការត្រៀមលក្ខណៈអនុវត្តរេដបូកនៅកម្ពុជា។

៥. សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ដើរតួនាទីយ៉ាងសំខាន់ គាំទ្រដល់ការអនុវត្តរេដបូកនៅកម្ពុជា។ ក៏ប៉ុន្តែ សហគមន៍ទាំងនេះបាននឹងកំពុងជួបប្រទះនឹងបញ្ហាប្រឈមពីការបំលែងព្រៃសហគមន៍ (នៅក្នុងពេលកំពុងដំណើរការ និងរង់ចាំទទួលបានការទទួលស្គាល់ស្របច្បាប់ និងការចុះកិច្ចព្រមព្រៀង)ទៅជាដីសម្បទានសេដ្ឋកិច្ច។ លើសពីនេះទៀត ជារឿយៗ សហគមន៍មិនអាចមានលទ្ធភាពរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិដោយខ្លួនឯងបានឡើយ ដោយសារតែលក្ខខណ្ឌបច្ចេកទេស និងហិរញ្ញវត្ថុមានភាពស្មុគស្មាញ។ ការគាំទ្រដល់ការអនុវត្តផែនការសហគមន៍ និងការផ្តល់ការគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងការពង្រឹងរចនាសម្ព័ន្ធសហគមន៍ព្រៃឈើក៏នៅមានកម្រិត។កម្មវិធីរេដបូកគួរពន្លឿនសកម្មភាពរៀបចំ និងផ្តល់ការគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍។

## ដំណើរការពិគ្រោះយោបល់រៀបចំយុទ្ធសាស្ត្ររេដបូកជាតិ

| **សកម្មភាព** | **កាលបរិច្ឆេទ** |
|---|---|
| គ្រោងឆ្អឹងនៃយុទ្ធសាស្ត្រ | ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៤ |
| សេចក្តីព្រាងដំបូង | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ |
| សេចក្តីព្រាងលើកទីពីរ/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ជាមួយ TF TTs CG GG | ថ្ងៃទី ២០-២១ ខែឧសភា ឆ្នាំ២០១៥ |
| សេចក្តីព្រាងលើកទី ៣/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី ២ ជាមួយ TF TTs CG GG | ថ្ងៃទី ៦-៨ ខែ កក្កដា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី៤/ឯកសារសាវតារ | ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិចំនួនបួនលើក៖<br>• ខេត្តក្រចេះ<br>• ខេត្តព្រះសីហនុ<br>• ខេត្តបាត់ដំបង<br>• ខេត្តសៀមរាប<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល នៅថ្នាក់ខេត្ត សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច) | ថ្ងៃទី ០៨-០៩ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ១៥-១៦ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២២-២៣ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ/ ភ្នំពេញ<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ TF TTs CG និង GG) | សប្តាហ៍ទីបី ខែតុលា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី ៥/ចុងក្រោយ/ ឯកសារសាវតារ | ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ |
| ការអនុម័តគាំទ្រដោយ MAFF/ MoE/ PM | នៅមុន COP 21 ទីក្រុងប៉ារីស |
| ការធ្វើបទបង្ហាញ/ការផ្សព្វផ្សាយយុទ្ធសាស្ត្ររេដបូកជាតិនៅក្នុង COP21 | ថ្ងៃទី ៣០ វិច្ឆិកា ដល់ ១១ ធ្នូ ២០១៥ |

សំគាល់៖ **TF**: ក្រុមការងាររេដបូក **TTs**: ក្រុមបច្ចេកទេស **CG**: ក្រុមពិគ្រោះយោបល់ **GG**: ក្រុមយេនឌ័រ


លេខាធិការដ្ឋានរេដបូកកម្ពុជា

Cambodia REDD+ Taskforce Secretariat
No. 40 Preah Norodom Blvd
Sangkat Psar Kandal 2, Khan Daun Penh, Phnom Penh, Cambodia
Tel: +855 023 224 251
Email: redd.secretariat@cambodia-redd.org
Website: Cambodia-redd.org
Facebook Page: Cambodia REDD+ National Programme